ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

# នាមនាមប្រជារាស្ត្រខ្មែរ

សំណុំរឿងរដ្ឋប្បវេណីលេខ៖០៤១
ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០
សាលក្រមលេខ៖ ២៧ (ថ)
ចុះថ្ងៃទី១៧/០៦/២០២០

សាលាដំបូងខេត្តកណ្ដាលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទីប្រាំបួន ខែមិថុនា ឆ្នាំពីរពាន់ម្ភៃ

## សមាសភាពជំនុំជម្រះ

- លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល
- លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

- ដើមចោទ លោក [redacted] សុផល ភេទប្រុស អាយុ៤០ឆ្នាំ មានអាសយដ្ឋាននៅភូមិ [redacted] ។

-តំណាងដោយអាណត្តិមានលោកមេធាវី [redacted] និងលោកមេធាវី [redacted]

- ចុងចម្លើយ លោកស្រី [redacted] បុទុម្ភ ភេទស្រី អាយុ៣៥ឆ្នាំ មានអាសយដ្ឋាន [redacted] ។

## អង្គហេតុ និងចំណុចវិវាទ

១. សាលក្រមដែលទាមទារដោយដើមចោទ

ប្តឹងសុំឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចខាងក្រោម៖

១.សុំលែងលះពីប្រពន្ធឈ្មោះ [redacted] បុទុម្ភ

២.សុំផ្ដល់អាហារកិច្ចដល់កូនទាំងពីរ គឺឈ្មោះ [redacted] សុម៉ារតី ភេទស្រី អាយុ ០៦ឆ្នាំ និងឈ្មោះ [redacted] សុគន្ធនិសា ភេទស្រី អាយុ ០២ឆ្នាំ ។

២. ការពន្យល់គ្រួសៗអំពីរឿងក្តី

រឿងក្តីនេះ ជារឿងក្តីដែលដើមចោទប្តឹងសុំលែងលះពីចុងចម្លើយ និងសុំផ្ដល់សិទ្ធិអំណាចមេបាលើកូនស្រីជាអនីតិជន០២នាក់ឱ្យទៅចុងចម្លើយជាអ្នកគ្រប់គ្រង ទី១ ឈ្មោះ [redacted] សុម៉ារតី ភេទស្រី អាយុ ០៦ឆ្នាំ និងឈ្មោះ [redacted] សុគន្ធនិសា ភេទស្រី អាយុ ០២ឆ្នាំ ដោយហេតុថា ការរស់នៅមិនចុះសម្រុងគ្នា ក្រោមហេតុផលថា ដើមចោទមិនអាចទទួលយកបាន ការមើលងាយពីសំណាក់បងប្អូន សាច់ញាតិ និងប្រពន្ធដែលធ្វើឱ្យពិបាករស់នៅជាមួយគ្នា ដែលតែងតែបង្កឱ្យមានបញ្ហាក្នុងគ្រួសារ និងធ្វើឱ្យដើមចោទអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀតបាន។

៣. ចំណុចវិវាទ និងចំណុចគ្មានវិវាទ

៣.១. ចំណុចវិវាទ៖ គ្មាន ។

៣.២.ចំណុចគ្មានវិវាទ៖ គ្មាន។

Scanned with CamScanner

៤. ការអះអាងរបស់គូភាគី

៤.១. ការអះអាងរបស់ដើមចោទ

-ដើមចោទអះអាងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា៖

ក. ចំពោះការទាមទារចំណុចទីមួយៈ សុំលែងលះពីចុងចម្លើយ ដោយមូលហេតុការរស់នៅ ដើមចោទមិនអាចទទួលយកបាន ចំពោះការមើលងាយពីសំណាក់បងប្អូនសាច់ញាតិ និងប្រពន្ធ ដែលធ្វើឱ្យពិបាករស់នៅជាមួយគ្នា

ខ.ចំពោះការទាមទារចំណុចទីពីរៈ សុំប្រគល់សិទ្ធិគ្រប់គ្រងកូនចំនួនពីរនាក់ ឈ្មោះ [redacted] សុម៉ារ័ត្ន និងឈ្មោះ [redacted] សុគន្ធនិសា ឱ្យទៅចុងចម្លើយជាអ្នកគ្រប់គ្រង

គ.ចំពោះការទាមទារចំណុចទីបីៈ សុំផ្តល់អាហារកិច្ចចិញ្ចឹមបីបាច់ថែរក្សាកូន ៧០ (ចិតសិបដុល្លារអាមេរិក)ក្នុងមួយខែ ។

-ដើមចោទអះអាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា៖ ខ្លួនសុំលែងលះ ដោយសារតែរស់នៅមិនចុះសម្រុងនិងគ្នា ក្រោមហេតុផលថា ដើមចោទមិនអាចទទួលយកបានការមើលងាយពីសំណាកបងប្អូន សាច់ញាតិ និងប្រពន្ធ ដែលធ្វើឱ្យពិបាករស់នៅជាមួយនិងគ្នា ដែលតែងតែបង្កឱ្យមានបញ្ហាក្នុងគ្រួសារ និងធ្វើឱ្យដើមចោទអស់មនោសញ្ចេតនា ។

៤.២ ការអះអាងរបស់ចុងចម្លើយ

- ចុងចម្លើយអះអាងក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា៖

ក.ចំពោះការទាមទារចំណុចទីមួយៈខ្លួនមិនឯកភាពការលែងលះទេ ដោយមូលហេតុកូនៗស្រលាញ់ប៉ាខ្លាំងណាស់ ខ្លួនមិនចង់ឱ្យមានការបែកបាក់គ្រួសារទេដោយសារអាណិតកូន

ខ.ចំពោះការទាមទារចំណុចទីពីរៈ បើសិនតុលាការសម្រេចឱ្យមានការលែងលះខ្លួនទទួលយកសិទ្ធិអំណាចមេបានេះ

គ.ចំពោះសោហុយចិញ្ចឹមបីបាច់ថែរក្សាកូនៈ ក្នុង១ខែ ៧០ដុល្លារ(ចិតសិបដុល្លារអាមេរិក)ខ្លួនសុខចិត្តទទួលយក ។

-ចុងចម្លើយអះអាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា៖ ខ្លួនមិនឯកភាពការលែងលះនេះទេ ព្រោះកូនៗស្រលាញ់ប៉ាខ្លាំងណាស់ ខ្លួនមិនចង់ឱ្យមានការបែកបាក់គ្រួសារទេ ដោយសារតែអាណិតកូន ប៉ុន្តែបើសិនជាតុលាការសម្រេចឱ្យមានការលែងលះ គឺនាងខ្ញុំទទួលយកសិទ្ធិអំណាចមេបា និងព្រមទទួលយកអាហារកិច្ចដើម្បីចិញ្ចឹមកូនមួយខែ ៧០ដុល្លារ(ចិតសិបដុល្លារអាមេរិក)។

## **សំអាងហេតុ**

តាមលទ្ធផលនៃការសាកសួរសាមីភាគី និងពិនិត្យភស្តុតាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា៖

១-យោងសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខៈ ០០៣ អ.ព ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០២០ បញ្ជាក់ថា ដើមចោទឈ្មោះ [redacted] សុផល និងចុងចម្លើយឈ្មោះ [redacted] មុទុម្ភ ពិតជាប្តីប្រពន្ធនឹងគ្នាតាមច្បាប់តាំងពីថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ប្រាកដមែន។

Scanned with CamScanner

២-ដើមចោទសុំលែងលះពីចុងចម្លើយ ដោយសារការរស់នៅជាមួយគ្នាពុំចុះសម្រុង និងអស់មនោសញ្ចេតនាជាប្តីប្រពន្ធនឹងគ្នាជាមួយចុងចម្លើយតទៅទៀត នោះសាលាដំបូងយល់ឃើញថា សហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ផ្ទុយនិងគោលបំណង់នៃអាពាហ៍ពិពាហ៍ហើយទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ និងគ្មានសង្ឃឹមថានឹងអាចធ្វើបដិទានឡើងវិញបានទេ ដូចនេះគប្បីសម្រេចឱ្យដើមចោទនិងចុងចម្លើយលែងលះគ្នាយោងតាមបញ្ញត្តិមាត្រា ៩៧៨ កថាខណ្ឌទី១ ចំណុច "ឃ" និង "ង" នៃក្រមរដ្ឋប្បវេណី។

៣-យោងសំបុត្រកំណើតលេខៈ ៨៧ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៣ និងសំបុត្រកំណើតលេខៈ ៥៨ សតខ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ បញ្ជាក់ថា ឈ្មោះ [redacted] **សុម៉ាវត្តី** ភេទស្រី កើតនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៣ និងឈ្មោះ [redacted] **សុគន្ធនិសា** ភេទស្រី កើតនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៧ ពិតជាកូនរបស់ដើមចោទ និងចុងចម្លើយ ប្រាកដមែន។

៤-តាមការអះអាងរបស់ភាគីទាំងពីរដែលថា ចំពោះសិទ្ធិគ្រប់គ្រងកូន គឺដើមចោទបានសុំប្រគល់សិទ្ធិគ្រប់គ្រងកូនទាំងពីរនាក់ឱ្យទៅចុងចម្លើយជាអ្នកគ្រប់គ្រង ភាគីចុងចម្លើយឯកភាពតាមដើមចោទ ដូច្នេះគប្បីតុលាការសម្រេចប្រគល់ឱ្យចុងចម្លើយជាអ្នកមានសិទ្ធិអំណាចមេបាលើកូនទាំងពីរនាក់ដែលមានឈ្មោះ [redacted] **សុម៉ាវត្តី** ភេទស្រី កើតនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៣ និងឈ្មោះ [redacted] **សុគន្ធនិសា** ភេទស្រី កើតនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៧ យោងតាមបញ្ញត្តិមាត្រា ១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

៥-គូភាគីមិនបានកំណត់ពីវិធីប្រាស្រ័យទាក់ទងកូន គប្បីតុលាការជាអ្នកកំណត់ដោយឆន្ទានុសិទ្ធិផ្អែកតាមមាត្រា១០៤០ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី ដែលតុលាការកំណត់ដូចខាងក្រោមៈ

ក.ចូលជួប ប្រាស្រ័យទាក់ទងជាមួយកូនរៀងរាល់ថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ថ្ងៃបុណ្យជាតិ និងថ្ងៃឈប់សម្រាកផ្សេងៗ ចាប់ពីវេលាម៉ោង ០៧ (ប្រាំពីរ) ព្រឹក រហូតដល់ម៉ោង ១៧ (ដប់ប្រាំពីរ) ល្ងាច។

ខ.ហាមឃាត់ដើមចោទឈ្មោះ [redacted] **សុផល** ដែលជាឪពុក ចូលជួបប្រាស្រ័យទាក់ទងជាមួយកូននៅក្នុងស្ថានភាពស្រវឹង។

គ.ការកំណត់នៅចំនុច ក និងចំនុច ខ នេះត្រូវគោរពទៅតាមឆន្ទៈរបស់កូនៗ ។

៦-សោហ៊ុយដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូន ចុងចម្លើយឈ្មោះ [redacted] **បុទុម្ភ** ទាមទារចំនួន ១០០ (មួយរយដុលារអាមេរិក) តែដើមចោទឈ្មោះ [redacted] **សុផល** មានលទ្ធភាពចិញ្ចឹមកូនក្នុងមួយខែ ៧០ (ចិតសិបដុល្លារអាមេរិក) ។ បើពិនិត្យមើលទៅតាមស្ថានភាពជាក់ស្តែងចុងចម្លើយបានយល់ព្រមទទួលយកអាហារកិច្ចពីដើមចោទ ៧០ (ចិតសិបដុល្លារអាមេរិក) ក្នុងមួយខែ ដូច្នេះគប្បីតុលាការធ្វើការសម្រេចតាមការព្រមព្រៀងនេះ ។

៧-ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១.ឱ្យដើមចោទ និងចុងចម្លើយលែងលះគ្នាចាប់ពីពេលនេះតទៅ ។

២.ប្រគល់សិទ្ធិអំណាចមេបាលើកូន ០២នាក់ កូនទី១ឈ្មោះ [redacted] **សុម៉ាវត្តី** ភេទស្រី ដែលយោងសំបុត្រកំណើតលេខៈ ៨៧ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៣ និងឈ្មោះ [redacted] **សុគន្ធនិសា** ភេទស្រី មាន

Scanned with CamScanner

សំបុត្រកំណើតលេខៈ ៥៨ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៧ ទៅឱ្យចុងចម្លើយតាមការព្រមព្រៀងរបស់គូភាគី ។

៣.ទុកសិទ្ធិឱ្យដើមចោទជាឪពុកឈ្មោះ [redacted] សុផល ៖

ក.ចូលជួប ប្រាស្រ័យទាក់ទងជាមួយកូនរៀងរាល់ថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ថ្ងៃបុណ្យជាតិ និងថ្ងៃឈប់សម្រាកផ្សេងៗ ចាប់ពីវេលាម៉ោង ០៧ (ប្រាំពីរ) ព្រឹក រហូតដល់ម៉ោង ១៧ (ដប់ប្រាំពីរ) ល្ងាច។

ខ.ហាមឃាត់ដើមចោទឈ្មោះ [redacted] សុផល ដែលជាឪពុក ចូលជួបប្រាស្រ័យទាក់ទងជាមួយកូននៅក្នុងស្ថានភាពស្រវឹង។

គ.ការកំណត់នៅចំនុច ក និងចំនុច ខ នេះត្រូវគោរពទៅតាមឆន្ទៈរបស់កូនៗ ។

៤.បង្គាប់ឱ្យដើមចោទបង់អាហារកិច្ចចំនួន ៧០(ដុល្លារអាមេរិក)ក្នុងមួយខែទៅឱ្យកូនរហូតដល់កូនមានវ័យនីតិភាព ។

៥.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះ បានទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០ ចំពោះមុខគូរភាគី ។

- ទុកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និងត្រាៈ [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១២ រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

កណ្តាល ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០

**បានឃើញ**

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner